# សេចក្តីសង្ខេបអំពី របៀបបណ្តេញចេញពីសាលារៀន

ការបណ្តេញចេញគឺ * ត្រូវដកសិស្សដាច់ខ្ទាត់ចេញពីការគ្រប់គ្រង និងការត្រួតត្រា, ឬការគ្រប់គ្រងទូទៅពីបុគ្គលិកសាលារៀន។ ការបណ្តេញចេញ សិស្សមិនអាចចូលរួមជាមួយកម្មវិធីរបស់ក្រសួងអប់រំប្រចាំក្រុង ឬចូលរួមជាមួយសកម្មភាពអ្វីមួយបាន, រួមទាំងកម្មវិធីសិក្សាដោយផ្ទាល់ការ *។ សិស្សមិនអាចទទួលការបណ្តេញចេញពីសាលារៀនបានទេលើកលែងតែមានការសម្រេចថា សិស្សបានប្រព្រឹត្តល្មើសនឹងច្បាប់ណាមួយ ឬលើសពីនេះដែលបណ្តាលឲ្យមានការបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀនក្រោមទម្រង់ច្បាប់គ្រប់គ្រងលេខ ៦២៩៥ ការបណ្តេញសិស្សពីសាលារៀនជាច្បាប់ក្រសួងអប់រំប្រចាំក្រុង។ ច្បាប់នេះអាចស្នើសុំពីសាលារៀនរបស់កូនលោកអ្នក ឬចូលទៅក្នុង website: www.sandi.net/policy/.

យោងទៅតាមការស្នើសុំដែលធ្វើឡើងដោយគណៈកម្មការគ្រប់គ្រង គណៈកម្មការក្រសួងអប់រំអាចដាក់បញ្ជាបណ្តេញសិស្សចេញពីសាលារៀន បើគេរកឃើញថា សិស្សបានប្រព្រឹត្តល្មើសដែលត្រូវបណ្តេញចេញពីសាលារៀន ហើយមានការស្នើសុំបណ្តេញសិស្សចេញដែរ។

**នៅក្នុងរយៈពេលសិក្សា សាមសិបថ្ងៃ (៣០) ខាងក្រោម ឬបុគ្គលិកចាត់តាំងសម្រេចថា សិស្សបានប្រព្រឹត្តល្មើសច្បាប់វិន័យដែលគួរបណ្តេញចេញពីសាលារៀន ហើយសិស្សមានសិទ្ធិចូលរួមស្តាប់គណៈកម្មការក្រសួងអប់រំធ្វើការសម្រេចចិត្តបណ្តេញសិស្សចេញពីសាលារៀន ឬយ៉ាងណា។**

សិស្សមានសិទ្ធិទទួលការផ្អាកមួយរយៈក្នុងការចូលរួមប្រជុំតវ៉ាដោះស្រាយអំពី ការបណ្តេញចេញពីសាលារៀន។ ពេលចាប់ផ្តើមការប្រជុំតវ៉ា គេនឹងមិនពន្យារពេលឡើយ។

លិខិតបញ្ជាក់អំពី ការតវ៉ាត្រូវតែផ្ញើដោយសិស្សក្នុងរយៈពេលដប់ថ្ងៃ (១០) មុនថ្ងៃតវ៉ា។ លិខិតបញ្ជាក់ត្រូវតែមានរួមមានៈ

- ថ្ងៃខែ និងទីកន្លែងប្រជុំតវ៉ា។
- រឿងរ៉ាវពិតប្រាកដ និងការចោទប្រកាន់ដែលគប្បីឲ្យបណ្តេញចេញពីសាលារៀន។
- លិខិតចម្លងស្តីអំពី ច្បាប់វិន័យណែនាំដែលទាក់ទងនឹងការប្រព្រឹត្តល្មើសច្បាប់វិន័យ។
- សិស្ស ឬមាតាបិតា/អ្នកអាណាព្យាបាលមានឱកាសតវ៉ាផ្ទាល់ និង/ឬជួលមេធាវីមកជាតំណាងដើម្បីដោះស្រាយ។
- មានសិទ្ធិពិនិត្យមើល និងទទួលឯកសារចម្លងសំរាប់ប្រើប្រាស់ នៅពេលធ្វើការតវ៉ា។
- មានឱកាសតវ៉ា និងសួរដេញដោលទៅលើសាក្សីដែលបានឆ្លើយ នៅពេលតវ៉ា និងសួរដេញដោលទៅលើភស្តុតាងដែលបានបង្ហាញទាំងអស់។
- មានឱកាសបង្ហាញនូវភស្តុតាងដែលសិស្សមាន រួមទាំងនាំសាក្សីមកឆ្លើយផងដែរ។

គណៈកម្មការស៊ើបអង្កេតការបណ្តេញសិស្សចេញពីសាលារៀនមានសមាជិកគណៈកម្មការក្រសួងអប់រំយ៉ាងហោចណាស់ចំនួន បីនាក់ ហើយបុគ្គលិកទាំងនោះមិនត្រូវធ្វើការនៅតាមសាលារៀនដែលសិស្សរៀនឡើយ។ ការប្រជុំនោះនឹងបិទមិនអោយសាធារណៈជនបានដឹងឡើយ លើកលែងតែមាតាបិតា/អ្នកអាណាព្យាបាលសិស្សសរសេរលិខិតស្នើសុំឲ្យមានការប្រជុំជាសាធារណៈ។ ការប្រជុំតវ៉ានឹងត្រូវកត់ត្រាទុក ហើយសិស្សមានសិទ្ធិសរសេរនូវសម្ភារៈហេតុការយកបង្ហាញឲ្យគណៈកម្មការត្រួតពិនិត្យមើលបានដែរ។

គណៈកម្មការស៊ើបអង្កេតការបណ្តេញសិស្សពីសាលារៀនត្រូវតែធ្វើការសម្រេចចិត្តថា តើត្រូវស្នើសុំដល់គណៈកម្មការក្រសួងអប់រំប្រចាំក្រុងបណ្តេញសិស្សចេញពីសាលារៀន។

## សង្ខេប

- សិស្សមិនអាចទទួលការបណ្តេញចេញពីសាលារៀន លើកលែងតែគេសម្រេចថា សិស្សបានប្រព្រឹត្តល្មើសនឹងច្បាប់អ្វីមួយ ឬលើសពីនេះដែលបណ្តាលអោយបញ្ឈប់ការមករៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀនក្រោមទម្រង់ការគ្រប់គ្រងច្បាប់លេខ ៦២៩៥។
- សិស្សមានសិទ្ធិតវ៉ាក្នុងរយៈពេល ៣០ថ្ងៃ ពេលខាងសាលាធ្វើការសម្រេចថា សិស្សបានប្រព្រឹត្តល្មើសវិន័យ ហើយត្រូវតែទទួលលិខិតតវ៉ាអំពី ការបណ្តេញចេញនេះ។
- គណៈកម្មការស៊ើបអង្កេតការបណ្តេញសិស្សដោយឡែកមានសមាជិកក្រសួងអប់រំចំនួនបីនាក់យ៉ាងហោចណាស់ចូលរួម។
- ការតវ៉ាស្តីអំពី ការបណ្តេញសិស្សពីសាលារៀនត្រូវបិទមិនឲ្យសាធារណៈជនដឹង។ សិស្សនឹងបានទទួលសម្ភារៈទាំងអស់ដែលទាក់ទងនឹងការតវ៉ានេះ។
- គណៈកម្មការជាអ្នកសម្រេចស្នើសុំឲ្យគណៈកម្មការក្រសួងអប់រំបណ្តេញសិស្សពីសាលារៀន។ មានតែគណៈកម្មការក្រសួងអប់រំអាចបណ្តេញសិស្សបាន។
- គណៈកម្មការក្រសួងអប់រំអាចធ្វើការសម្រេចមិនបណ្តេញសិស្ស, បណ្តេញសិស្សចេញ ឬបញ្ឈប់សិស្សរៀនជាបណ្តោះអាសន្ន ហើយត្រូវតែមានគម្រោងដើម្បីណែនាំសិស្ស (ពីគ្រូប្រឹក្សា, ការណែនាំពីសុខភាពសហគមន៍, ក្រសួងរកការងារ។ល។)
- នៅពេលបណ្តេញពីសាលារៀន សិស្ស និងមាតាបិតា/អ្នកអាណាព្យាបាលសិស្សនឹងបានទទួលលិខិតបញ្ជាក់អំពី ការចុះឈ្មោះចូលរៀនឡើងវិញ និងពេលវេលាដែលត្រូវចុះឈ្មោះផងដែរ។
- ការបណ្តេញសិស្សពីសាលារៀនត្រូវធ្វើឡើង ហើយគណៈកម្មការក្រសួងអប់រំពន្យារការអនុវត្តន៍ដោយ ចុះឈ្មោះចូលរៀនឡើងវិញបាន។

- បន្ត -

* បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺលើកកម្ពស់ការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ក្រោមជំនួយការសិក្សារបស់សិស្សនៅតាមថ្នាក់រៀន។ *

បើគណៈកម្មការស៊ើបអង្កេតការបណ្តេញសិស្សចេញពីសាលារៀនសម្រេចចិត្តមិនបណ្តេញសិស្សចេញពីសាលារៀនទេនោះ ការបណ្តេញសិស្សចេញពីសាលារៀនត្រូវតែបញ្ឈប់តែម្តង។ សិស្សធ្វើការបញ្ជាក់ និងអនុញ្ញាតិឲ្យបន្ទាន់ដោយពុំពន្យារពេលចូលរៀននៅក្នុងកម្មវិធីសិក្សានៅតាមបន្ទប់រៀន, និងកម្មវិធីសិក្សាផ្សេងៗ, កម្មវិធីណែនាំ ឬមួយផ្សេងៗ កម្មវិធីទាំងនេះ។ ការិយាល័យតវ៉ា និងចំណាត់ថ្នាក់នោះស្រាយជាមួយគ្រូរបស់សិស្ស និងមាតាបិតា/អ្នកអាណាព្យាបាលសិស្សដើម្បីសម្រេចរៀបចំចំណាត់ថ្នាក់ឲ្យសិស្សចូលរួមជាមួយកម្មវិធីមួយ ឬផ្សេងទៀត។ ផងដែរបញ្ចប់នេះ ការសម្រេចចិត្តនឹងមិនបណ្តេញសិស្សចេញពីសាលារៀនទៀតទេ។

បើគណៈកម្មការស៊ើបអង្កេតការបណ្តេញសិស្សចេញពីសាលារៀនសម្រេចចិត្តបណ្តេញសិស្សចេញពីសាលារៀន គេនឹងបង្ហាញភស្តុតាងដើម្បីគាំទ្រការសម្រេចចិត្តនេះ ហើយផ្ញើជូនគណៈកម្មការក្រសួងអប់រំប្រចាំក្រុង។ មានតែគណៈកម្មការក្រសួងអប់រំប៉ុណ្ណោះអាចបណ្តេញសិស្សចេញពីសាលារៀនបាន។

យោងទៅតាមការបណ្តេញសិស្សចេញពីសាលារៀន គណៈកម្មការក្រសួងអប់រំត្រូវតែស្នើសុំឲ្យគម្រោងអប់រំសិស្ស។ គម្រោងការអប់រំសិស្សមានរួមការស៊ើបអង្កេត និងពិនិត្យមើលនៅពេលសិស្សចូលរៀនឡើងវិញ។ គម្រោងមានរួមទាំងការស្នើសុំឲ្យក្រសួងផ្នែកផ្តល់ប្រឹក្សា, ផ្នែកការងារ, ផ្នែកបំរើនៅតាមសហគមន៍ ឬកម្មវិធីផ្សេងៗ។ យោងទៅតាមការជ្រើសរើស គណៈកម្មការក្រសួងអប់រំអាចចាត់ឲ្យសិស្សចូលរៀននៅតាមសាលារៀន, ថ្នាក់ ឬកម្មវិធីដែលមានការសមរម្យសំរាប់សិស្សសិក្សាអប់រំ។ គណៈកម្មការក្រសួងអប់រំអាចបញ្ឈប់សិស្សជាបណ្តោះអាសន្ន យោងទៅតាមបញ្ហាពីការបណ្តេញសិស្សឲ្យឈប់រៀនពីសាលា។

មុនបញ្ចប់ពេលវេលានៃការបណ្តេញសិស្សចេញពីសាលារៀន សិស្សត្រូវតែទាក់ទងការិយាល័យតវ៉ា និងចំណាត់ថ្នាក់ដែលនឹងធ្វើការសម្រេចចំណាត់ថ្នាក់ដោយបានសមរម្យសំរាប់សិស្សចូលរៀនឡើងវិញ។ ការសម្រេចចិត្តនេះនឹងយកមកពិនិត្យមើលអំពើដែលសិស្សប្រព្រឹត្តខុសដែលបណ្តេញសិស្សចេញពីសាលារៀន និងសុវត្ថិភាព, សន្តិសុខ និងសុខមាលភាពរបស់បុគ្គលិកក្រសួងអប់រំ និងសិស្សដទៃទៀតនៅតាមសាលារៀន។

ការដាក់បញ្ហាបណ្តេញសិស្សចេញពីសាលារៀននៅតែមាន រហូតទាល់តែគណៈកម្មការក្រសួងអប់រំបញ្ជាឲ្យសិស្សចូលរៀនវិញបាន។

យោងទៅតាមការបញ្ចប់ការចូលរៀនឡើងវិញ គណៈកម្មការក្រសួងអប់រំប្រចាំក្រុងនឹងអនុញ្ញាតិឲ្យសិស្សចូលរៀនឡើងវិញ លើកលែងតែគណៈកម្មការក្រសួងអប់រំប្រចាំក្រុងរកឃើញថា សិស្សមិនបានប្រតិបត្តិតាមលក្ខណៈគម្រោងការណែនាំ ឬបន្តការធ្វើឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខសិស្សផ្សេងៗ ឬបុគ្គលិកការងាររបស់ក្រសួងអប់រំប្រចាំក្រុងនៅក្នុងសាលារៀន។ សិស្សនិងមាតាបិតា/អ្នកអាណាព្យាបាលនឹងទទួលលិខិតបញ្ជាក់អំពី ការចូលរៀនឡើងវិញ នៅពេលគណៈកម្មការក្រសួងអប់រំសម្រេចចិត្តបណ្តេញសិស្សចេញពីសាលារៀន។

បើគណៈកម្មការក្រសួងអប់រំបដិសេធមិនឲ្យសិស្សចូលរៀនឡើងវិញទេនោះ គណៈកម្មការក្រសួងអប់រំប្រចាំក្រុងត្រូវតែបន្តចំណាត់ថ្នាក់សំរាប់សិស្សសិក្សានៅក្នុងកម្មវិធីសិក្សាផ្សេងដែលត្រូវរចនាឡើងជ្រើសរើសសំរាប់សិស្សសិក្សា នៅរយៈពេលនៃបញ្ហាបណ្តេញសិស្សឲ្យឈប់រៀនពីសាលារៀនឬចាត់ឲ្យសិស្សរៀននៅក្នុងកម្មវិធីសំរាប់សិស្សដែលត្រូវគេបញ្ចេញចេញពីសាលារៀន។ នេះមានរួមទាំងចំណាត់ថ្នាក់ចូលរៀននៅតាមសាលារៀនសហគមន៍ប្រចាំស្រុក។ គណៈកម្មការក្រសួងអប់រំប្រចាំក្រុងត្រូវតែផ្តល់លិខិតដល់សិស្ស និងមាតាបិតា ឬអ្នកអាណាព្យាបាលអំពី ការបណ្តេញសិស្សចេញពីសាលារៀន ព្រមទាំងរៀបរាប់នូវហេតុផលដែលបដិសេធឲ្យសិស្សចូលរៀនឡើងវិញនៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំប្រចាំក្រុង។

ក្រោយពីសិស្សបានបញ្ចប់ការណែនាំបានសព្វគ្រប់ហើយ គណៈកម្មការក្រសួងអប់រំប្រចាំក្រុងនឹងអនុញ្ញាតិឲ្យសិស្សចូលរៀនវិញបាន។

បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ទាក់ទងព័ត៌មាន: ការិយាល័យចំណាត់ថ្នាក់ និងតវ៉ា (៦១៩) ៧២៥-៥៦០០
ការស្តាប់តាមសាលាគណៈ: (៦១៩) ៧២៥-៥៥៧៨
www.sandi.net

ការបំរើសិស្សជាង ១៣៨០០០នាក់, សាលារៀនប្រចាំក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០០ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (សំរាបបុគ្គលិកជាង ១៩០០០នាក់)។ SDCS ផ្តល់ការអប់រំសិស្សតាមនិរាញ្ញសាយការអប់រំផ្នែក រៀនភាគ, សាលា និងផលិតកម្មក្រសួងអប់រំប្រចាំក្រុងផ្តល់ជំនាញគាំទ្រសាលារៀន និងជំនួយមិនបាតការសំរាប់សិស្សសិក្សានៅតាមបន្ទប់រៀនដោយផ្តល់រៀបចំផ្លូវសិក្សា និងទទួលខុសត្រូវពីមាននូវទៅ និងដោយមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

" ទស្សនវិស័យរបស់ក្រសួងអប់រំប្រចាំក្រុង សាន់ឌីអេហ្គោ គឺផ្តល់ការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "

Summary of the Expulsion Process. Cambodian.